**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ៦០០៧ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមការងារសកម្មភាពជនពិការក្រសួងមហាផ្ទៃ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញប្រកាសលេខ ០០១ កសជ.ប្រក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាសកម្មភាពជនពិការស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ន
- បានឃើញសេចក្ដីសម្រេចលេខ ១៨៩ សសរ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាសកម្មភាពជនពិការ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារសកម្មភាពជនពិការក្រសួងមហាផ្ទៃ ដែលមានឈ្មោះជាអក្សរកាត់ថា «**ស.ជ.ម.ផ.**»។

**ប្រការ២.-**

សមាសភាព **ស.ជ.ម.ផ.** រួមមាន ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម អភិសន្តិបណ្ឌិត | **ស សុខា** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | **ប្រធានកិត្តិយស** |
| ២. ឯកឧត្តម | **យុន ឈុន្នី** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ប្រធាន |
| ៣. ឯកឧត្តម | **អ៊ុន សាខុន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល | **អនុប្រធាន** |
| ៤. ឯកឧត្តម | **ជា ម៉ិនហេង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល | **អនុប្រធាន** |
| ៥. ឯកឧត្តម | **ឈឹម កាន** | អគ្គនាយករងទទួលបន្ទុកជាប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ នៃអគ្គនាយកដ្ឋានរដ្ឋបាល | **អនុប្រធាន** |
| ៦. ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឡោ សុឡេង** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | **អនុប្រធាន** |
| ៧. ឯកឧត្តម ឧត្តមអគ្គានុរក្ស.១ | **តោ ពន្លក** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធនាគារ | **អនុប្រធាន** |
| ៨. ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ម៉ឹង ម៉ូរ៉ា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានធនធានមនុស្ស | **អនុប្រធាន** |
| ៩. ឯកឧត្តម ឧត្តមសេនីយ៍ឯក | **តាំង សេរីវឌ្ឍន៍** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន | **អនុប្រធាន** |
| ១០. ឯកឧត្តម | **ហូ ផល្លា** | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន | **អនុប្រធាន** |
| ១១. ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ណុប នរិន្ទ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | **អនុប្រធាន** |
| ១២. ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សួន ផល្លា** | អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា | **អនុប្រធាន** |
| ១៣. ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សុក្រឹត្យ ថនឥស្សរ៉ា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | **អនុប្រធាន** |
| ១៤. ឯកឧត្តម ឧត្តមសេនីយ៍ទោ | **ម៉ែន ម៉ុននិត្យ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកសុភារ និងហិរញ្ញវត្ថុ | **អនុប្រធាន** |
| ១៥. ឯកឧត្តម ឧត្តមសេនីយ៍ត្រី | **អ៊ិន សំអាត** | អនុប្រធានក្រុមប្រឹក្សានីតិកម្ម | **អនុប្រធាន** |
| ១៦. ឯកឧត្តម | **យិន សុវិនចិន្តា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | **អនុប្រធាន** |
| ១៧. លោក | **ឆាង ច័យ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត នៃអគ្គនាយកដ្ឋានរដ្ឋបាល | **សមាជិក** |
| ១៨. លោក | **លី យ៉ាសាក់** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៃអគ្គនាយកដ្ឋានរដ្ឋបាល | **សមាជិក** |
| ១៩. លោកស្រី | **ហេង ពៅធីតា** | ប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គនាយកដ្ឋានរដ្ឋបាល | **សមាជិក** |
| ២០. លោក ឧត្តមសេនីយ៍ទោ | **សេង វិសិដ្ឋ** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ | **សមាជិក** |
| ២១. លោក ឧត្តមសេនីយ៍ត្រី | **ជន ដារ៉ា** | អនុប្រធាននាយកដ្ឋានគោលនយោបាយ នៃអគ្គនាយកដ្ឋានធនធានមនុស្ស | **សមាជិក** |

២២. លោក វរសេនីយ៍ឯក **ទ៊ា ទ៊ាន់សាត់** នាយការិយាល័យគោលនយោបាយមន្ត្រីនគរបាលជាតិ

នាយកដ្ឋានគោលនយោបាយ នៃអគ្គនាយកដ្ឋានធនធានមនុស្ស **សមាជិក**

**ប្រការ៣.-**

**ស.ជ.ម.ផ.** មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម
- រៀបចំគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រដែលមានការពាក់ព័ន្ធទៅនឹងពិការភាព និងការស្តារលទ្ធភាពពលកម្ម
- ជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម
- លើកសំណើជូនក្រុមប្រឹក្សាសកម្មភាពជនពិការដើម្បីកែសម្រួល ធ្វើវិសោធនកម្មគោលនយោបាយច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាព
- តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាព
- ទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធ កៀរគរប្រភពធនធានទាំងក្នុង និងក្រៅប្រទេស
- ចូលរួម និងរៀបចំទិវាជនពិការជាតិ អន្តរជាតិ និងទិវាជនពិការផ្សេងៗទៀត
- ជួយក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពទាក់ទងពិការភាព
- ដឹកនាំ ចាត់ចែង អនុវត្ត និងធ្វើរបាយការណ៍បូកសរុបលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពជនមានពិការភាព ជូនក្រុមប្រឹក្សាសកម្មភាពជនពិការ
- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាសកម្មភាពជនពិការប្រគល់ឱ្យ។

**ប្រការ៤.-**

របៀបរបបការងាររបស់ **ស.ជ.ម.ផ.** រួមមាន៖

- រៀបចំកិច្ចប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំ។ ក្នុងករណីចាំបាច់អាចរៀបចំកិច្ចប្រជុំវិសាមញ្ញតាមការអញ្ជើញរបស់ប្រធាន
- រៀបចំផែនការសកម្មភាព និងផែនការថវិកា
- រៀបចំការបូកសរុបរបាយការណ៍ប្រចាំឆ្នាំ អំពីលទ្ធផល និងទិសដៅ នៃការអនុវត្តការងារសកម្មភាពជនពិការ ដាក់ជូនក្រុមប្រឹក្សាសកម្មភាពជនពិការ
- ប្រធាន **ស.ជ.ម.ផ.** ជាអធិបតី នៃរាល់កិច្ចប្រជុំ លើកលែងតែមានការផ្ទេរសិទ្ធិពីប្រធាន
- កិច្ចប្រជុំនានា អាចមានការចូលរួមពី តំណាងក្រសួង ស្ថាប័ននានា អង្គការមិនមែនរដ្ឋាភិបាល ជនមានពិការភាព ដៃគូអភិវឌ្ឍ និងផ្នែកឯកជនដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍តាមការចាំបាច់
- មានសិទ្ធិប្រើត្រារបស់ក្រសួងមហាផ្ទៃដើម្បីបំពេញការងារ។

**ប្រការ៥.-**

**ស.ជ.ម.ផ.** មានលេខាធិការដ្ឋានមួយជាសេនាធិការដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ជា ប៊ុនហេង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល | ប្រធាន |
| ២. ឯកឧត្តម ឧត្តមសេនីយ៍ឯក | **តាំង សេវិនរ័ប** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន | អនុប្រធាន |
| ៣. ឯកឧត្តម ឧត្តមសេនីយ៍ទោ | **ម៉ន ប៊ុននិត្យ** | អគ្គនាយករង នៃអគ្គនាយកដ្ឋាន ភស្តុភារ និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯកឧត្តម ឧត្តមសេនីយ៍ទោ | **ថ្លាំ ឧទ្ធី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | អនុប្រធាន |
| ៥. លោក ឧត្តមសេនីយ៍ទោ | **ឆាង សុឃាង** | ប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ៦. លោក ឧត្តមសេនីយ៍ត្រី | **វ័ន សុវណ្ណ** | ប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គាធិការដ្ឋាន | សមាជិក |
| ៧. លោក | **ឆាង វ័យ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៨. លោក | **លី យ៉ាសាក់** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៩. លោកស្រី | **ហេង ពៅធីតា** | ប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ១០. លោក | **វ៉ែន បញ្ញា** | ប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃក្រុមប្រឹក្សានីតិកម្ម | សមាជិក |
| ១១. លោក | **ញ៉ាវ តង** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ១២. លោក | **សុខ វាសនា** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ១៣. លោក ឧត្តមសេនីយ៍ត្រី | **គិន វិត្យា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក |
| ១៤. លោក ឧត្តមសេនីយ៍ត្រី | **ជន ជារ៉ា** | អនុប្រធាននាយកដ្ឋានគោលនយោបាយ នៃអគ្គនាយកដ្ឋានធនធានមនុស្ស | សមាជិក |
| ១៥. លោក វរសេនីយ៍ឯក | **ភង សោភ័ណ** | អនុប្រធាននាយកដ្ឋានវិទ្យុទាក់ទង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៦. លោក វរសេនីយ៍ឯក | **ផូ ស៊ីយ៉ា** | អនុប្រធានមន្ទីរចាត់ការ នៃបណ្ឌិត្យសភានគរបាលកម្ពុជា | សមាជិក |
| ១៧. លោក ឧត្តមសេនីយ៍ត្រី | **ណុប ចាន់ធី** | នាយការិយាល័យ នៃអគ្គនាយកដ្ឋាន បច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ | សមាជិក |

១៨. លោក វរសេនីយ៍ឯក **អ៊ា អ៊ាន់សាក់** នាយការិយាល័យគោលនយោបាយមន្ត្រីនគរបាលជាតិ នាយកដ្ឋានគោលនយោបាយ នៃអគ្គនាយកដ្ឋានធនធានមនុស្ស **សមាជិក**

១៩. លោក វរសេនីយ៍ត្រី **យឹម វឌ្ឍនៈ** ជំនួយការ ឯកឧត្តម **យុន ឈុន្នី** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ **សមាជិក**

**ប្រការ៦.-**

លេខាធិការដ្ឋាន **ស.ជ.ម.ផ.** មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ជាសេនាធិការជូនក្រុមការងារ **ស.ជ.ម.ផ.** និងផ្ដើមស្នើគោលការណ៍ វិធានការនានា ដើម្បីកិច្ចដំណើរការ **ស.ជ.ម.ផ.** ទទួលបានជោគជ័យ
- រៀបចំកម្មវិធីប្រជុំ និងបំពេញកិច្ចការរដ្ឋបាលពាក់ព័ន្ធដល់កិច្ចដំណើរការ **ស.ជ.ម.ផ.**
- រៀបចំគម្រោងថវិកា មធ្យោបាយ សម្ភារ ប្រចាំឆ្នាំ សម្រាប់បម្រើការងារដល់ **ស.ជ.ម.ផ.**
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមការងារ

**ប្រការ៧.-**

សេចក្ដីសម្រេចលេខ ១០២៣៥ សសរ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ស្ដីពីការបង្កើតក្រុមការងារសកម្មភាពជនពិការក្រសួងមហាផ្ទៃ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គាធិការ នៃអគ្គាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយក នៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ប្រធានក្រុមប្រឹក្សានីតិកម្ម អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ និងសមាសភាព ដូចមានចែងក្នុងប្រការ២ និងប្រការ៥ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.អង្គារ ១៤ កើត.ខែ.មិគសិរ..ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ.ធ្នូ....... ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល ÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន ក.ស.ជ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ